**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 10-Aug-2011, 14:42
CMS/CFO: Uch Arun

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៥ ខែ សីហា ឆ្នាំ ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ **សាធារណៈ:/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើរបស់លោក អៀង សារី ស្នើសុំការអនុញ្ញាតដើម្បីឆ្លើយតប**

**និង**

**ការឆ្លើយតបទៅនឹងសារណារបស់ដើមបណ្តឹងរដ្ឋប្បវេណីគាំទ្រដល់សំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យអង្គជំនុំជម្រះសាលាដំបូងប្រកាសទទួលស្គាល់ទម្រង់ទីបីនៃសហឧក្រិដ្ឋរួមជាជម្រើសមួយទៀតនៃទម្រង់នៃការទទួលខុសត្រូវ**

---

**ដាក់ដោយ៖**

**សហមេធាវី៖**

អាង ឧត្តម

Michael G. KARNAVAS

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម **និល ណុន** ប្រធាន

ចៅក្រម **ធូ មណី**

ចៅក្រម **យ៉ា សុខន**

ចៅក្រម Silvia CARTWRIGHT

---

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបម្រុង **យូរ ឧត្តរា**

ចៅក្រមបម្រុង Claudia FENZ

**សហព្រះរាជអាជ្ញា៖**

ជា លាង

Andrew CAYLEY

**ក្រុមមេធាវីការពារក្ដីទាំងអស់**

**ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់**

00724847



០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

# សំណើសុំការអនុញ្ញាតដើម្បីឆ្លើយតប

លោក អៀង សារី តាមរយៈសហមេធាវីរបស់គាត់(“សហមេធាវីការពារក្តី”) ស្នើសុំការអនុញ្ញាតដើម្បីឆ្លើយតបទៅនឹងសារណារបស់ដើមបណ្តឹងរដ្ឋប្បវេណី គាំទ្រដល់សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូងប្រកាសទទួលស្គាល់ទម្រង់ទីបីនៃសហឧក្រិដ្ឋរួម ជាជម្រើសមួយទៀតនៃទម្រង់ទទួលខុសត្រូវ(“សារណា”)[១]។ ការឆ្លើយតបនេះគឺជាការចាំបាច់ ដ្បិតសារណានោះធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងយល់ខុស ដោយសន្និដ្ឋានថាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់គាំទ្រទឡ្ហីករណ៍របស់ការិយាល័យសហព្រះរាជអាជ្ញា(“ក.ស.ព”) ពាក់ព័ន្ធនឹងការអនុវត្តសហឧក្រិដ្ឋកម្មរួម និងជាពិសេសទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួមនៅ អ.វ.ត.ក។ សារណានោះបានគូសបញ្ជាក់ថា“សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី យល់ឃើញថាទម្រង់ទាំងបីនៃការទទួលខុសត្រូវក្នុងសហឧក្រិដ្ឋកម្មរួម មានលក្ខណៈសមស្របទៅនឹងការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ”[២]។ ចំណុចនេះផ្ទុយទៅនឹងអ្វីដែលបានផ្ទុះបញ្ឆាំងក្នុង(កំណត់ហេតុ)សំណុំរឿង ០០១។ ដើមបណ្តឹងរដ្ឋប្បវេណីជាក់លាក់មួយចំនួន បានសម្តែងមតិ*ក្នុងករណីនេះ* និងក្នុងសំណុំរឿង ០០១ ថាពួកគាត់បានចាត់ទុកថារាល់ទម្រង់នៃការទទួលខុសត្រូវក្នុងសហឧក្រិដ្ឋកម្មរួម និងដែលក.ស.ពចង់លើកស្នួយឱ្យអនុវត្ត មិនអាចអនុវត្តបានឡើយនៅចំពោះមុខ អ.វ.ត.ក[៣]។ ជាការពិត ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នេះ បានប្រកាន់ជំហរមួយស្របគ្នាទៅនឹងជំហរអង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងភាពមិនអាចអនុវត្តបាននៃទម្រង់ទីបីនៃសហឧក្រិដ្ឋ

[១] សារណាគាំទ្រសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូង ប្រកាសថាទទួលស្គាល់ទម្រង់ទីបីនៃសហឧក្រិដ្ឋរួមថាជាជម្រើសមួយនៃទម្រង់នៃការទទួលខុសត្រូវ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១១ E100/4។

[២] ដូចខាងលើ កថាខណ្ឌ ២

[៣] *សូមមើល* សារណាតបរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្តីពីសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៨ D97/3/4។ *សំណុំរឿងរបស់ កាំង ហ្កេកអ៊ាវ “ឌុច”* 001/18-07-2007-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ ០២) សារណាតបរបស់សហមេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងសារណារបស់អ្នកដែលមិនមែនភាគីក្នុងរឿងក្តី ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨ D99/3/32។ *សំណុំរឿងរបស់ កាំង ហ្កេកអ៊ាវ “ឌុច”* 001/18-07-2007- អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ-កាំង ហ្កេកអ៊ាវ “ឌុច” សាធារណៈ- កោសលុប ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៩ E1/78.1, ទំព័រទី ៦, ១.១-៩។ *សូមមើល* ការឆ្លើយតបខាងក្រោម ដើម្បីជ្រាបអំពីគំនិតពិស្តារបន្ថែម។

កម្ពុជា[៤] និងស្របគ្នាទៅនឹងអ្វីដែលក្រុមសហមេធាវីការពារក្តី បានលើកឡើងនៅក្នុងសារណាតបទៅនឹងសំណើរបស់ ក.ស.ព សុំ"កំណត់"អង្គហេតុសាជាថ្មី ដើម្បីបញ្ចូលការទទួលខុសត្រូវទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម[៥]។ សារណានោះពុំបានរៀបរាប់អំពីជំហរខុសគ្នាក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីទេ និងពុំបានផ្តល់សេចក្តីពន្យល់នៅក្នុងសារណា អំពីថាតើជំហរពីមុននិងជំហរឥឡូវអាចបញ្ចូលគ្នាបានដោយរបៀបណានោះទេ។ ជាការចំបាច់ គេត្រូវជម្រាបអង្គជំនុំជម្រះសាលាដំបូងឱ្យយកចិត្តទុកដាក់លើជំហររបស់ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនកាលពីពេលកន្លងទៅ ដើម្បីបានជាប្រយោជន៍ដល់ភាពត្រឹមត្រូវ សុចរិតធម៌ និងភាពគ្រប់ជ្រុងជ្រោយ។ គេសន្មតបានថា នៅពេលសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះ ដើរតួតំណាងឱ្យស្ថាប័នតុលាការនៃ អ.វ.ត.ក ពាក់ព័ន្ធនឹងបញ្ហាច្បាប់ ជាពិសេសពាក់ព័ន្ធនឹងភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួមនៅ អ.វ.ត.ក ពួកគាត់ច្បាស់ជាធ្វើដូច្នេះឆ្លងតាមការពិចារណាល្អិតល្អន់ និងក្នុងបំណងល្អ។ សហមេធាវីការពារក្តីសូមភ្ជាប់ការឆ្លើយតបរបស់ខ្លួន ដូចតទៅនេះ ដើម្បីជាប្រយោជន៍ដល់សេដ្ឋកិច្ច និងភាពឆាប់រហ័សនៃតុលាការ។

## ការឆ្លើយតប

### I- សាវតារ

---

[៤] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីការបស់សហចៅក្រមស៊ើបអង្កេតស្តីពីសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ D97/14/15។

[៥] ចម្លើយតបរបស់លោក អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំអង្គជំនុំជម្រះសាលាដំបូងប្រកាសទទួលស្គាល់ទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួមថាជាជម្រើសមួយទៀតនៃទម្រង់នៃការទទួលខុសត្រូវ និងសំណើសុំសវនាការផ្ទាល់មាត់ ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ E100/2។ [ខៀវ សំផន] Réponse à la Demande des Co-Procureurs Relative à la Troisième Catégorie d'Entreprise Criminelle Commune, ២២ ខែ កក្កដា ឆ្នាំ ២០១១, E100/3។ [អៀង ធីរិទ្ធ] ចម្លើយតបរបស់សហមេធាវីការពារក្តី តបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូងប្រកាសទទួលស្គាល់ទម្រង់ទីបីនៃសហឧក្រិដ្ឋរួម ជាជម្រើសមួយទៀតនៃទម្រង់នៃការទទួលខុសត្រូវ ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ E100/1។ [នួន ជា] សារណាតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូងប្រកាសទទួលស្គាល់ទម្រង់ទីបីនៃសហឧក្រិដ្ឋរួម ជាជម្រើសមួយទៀតនៃទម្រង់នៃការទទួលខុសត្រូវ ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ E100/5។

00724849



១ នៅថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៨ សហមេធាវីការពារក្តី បានដាក់ពាក្យសុំមួយក្នុងសំណុំរឿង ០០២ ទៅកាន់ការិយាល័យសហចៅក្រមស៊ើបអង្កេត ប្រឆាំងនឹងការអនុវត្តរាល់ទម្រង់នៃសហឧក្រិដ្ឋកម្មរួមនៅ អ.វ.ត.ក[៦]។

២ នៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៨ សហព្រះរាជអាជ្ញាបានឆ្លើយតបទៅនឹងពាក្យសុំរបស់សហមេធាវីការពារក្តី ដោយអះអាងថារាល់ទម្រង់នៃការទទួលខុសត្រូវក្នុងសហឧក្រិដ្ឋកម្មរួម សុទ្ធតែអាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក[៧]។

៣ នៅថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០០៨ ការិយាល័យសហចៅក្រមស៊ើបអង្កេត បានចេញដីកាមួយអនុញ្ញាតឲ្យភាគីទាំងអស់ ដាក់សារណាបន្ថែមស្តីពីភាពអាចអនុវត្តបាននៃការទទួលខុសត្រូវនៃសហឧក្រិដ្ឋកម្មរួមនៅ អ.វ.ត.ក[៨]។

៤ នៅថ្ងៃទី ២៣ និង ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ អង្គបុរេជំនុំជម្រះ ក្នុងសំណុំរឿង ០០១ បានស្វះស្វែងរកជំនួយពីខាងក្រៅ ពាក់ព័ន្ធនឹងទឡ្ហីករណ៍របស់ ក.ស.ព ស្តីពីបណ្តឹងឧទ្ធរណ៍ដែលថា ការទទួលខុសត្រូវនៃសហឧក្រិដ្ឋកម្មរួម គប្បីដាក់បញ្ចូលក្នុងដីកាដំណោះស្រាយនៃសំណុំរឿង ០០១ ដោយបានស្នើសុំសារណាពីសាស្រ្តាចារ្យ Antonio Cassese ដែលជាអ្នកមិនមែនភាគីនៃរឿងក្តី និងសមាជិកនៃក្រុមប្រឹក្សានិពន្ធនៃទិនានុប្បវត្តិនៃយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ[៩] មជ្ឈមណ្ឌលសម្រាប់

[៦] ពាក្យសុំរបស់លោក អៀង សារី ប្រឆាំងនឹងការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវ ដែលគេហៅថា *សហឧក្រិដ្ឋកម្មរួម* ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៨ D97។

[៧] សារណាតបរបស់សហព្រះរាជអាជ្ញា ទៅនឹងពាក្យសុំរបស់លោក អៀង សារី ស្តីពីសហឧក្រិដ្ឋកម្មរួម D97/2 ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៨។

[៨] ដីកាសម្រេចលើពាក្យសុំស្តីពីទម្រង់នៃការទទួលខុសត្រូវ ដែលមានឈ្មោះថា សហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០០៨ D97/III។

[៩] *សំណុំរឿងរបស់ កាំង ហ្គេកអ៊ាវ "ឌុច"* 001/18-07-2007-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ ០២) សេចក្តីអញ្ជើញអ្នកដែលមិនមែនភាគីនៃរឿងក្តី ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០០៨ D99/3/12។ នៅថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០០៨ សហមេធាវីការពារក្តី

> សិទ្ធិមនុស្ស និងពហុនិយមគតិយុត្តិនៃសាកលវិទ្យាល័យ McGill University និងសាស្ត្រាចារ្យបណ្ឌិត Kai Ambos នៃសាកលវិទ្យាល័យ the Georg-August Universität Göttingen[១០]។ សារណារបស់ពួកគាត់ត្រូវបានដាក់នៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៨[១១]។

---

បានដាក់ពាក្យសុំនៅចំពោះមុខអង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០១ សុំប្ដឹងជំទាស់ឧត្តមបើនឹងលោកសាស្ត្រាចារ្យ Cassese និងសមាជិកជាក់លាក់មួយចំនួននៃក្រុមប្រឹក្សានិពន្ធ ដោយពន្យល់ថាពួកគាត់ពុំមានលក្ខណ:សម្បត្តិដើម្បីបញ្ចេញមតិដោយឥតលម្អៀងមួយលើបញ្ហាសហឧក្រិដ្ឋកម្មរួមនេះបាននោះទេ។ *សំណុំរឿងរបស់ កាំង ហ្គេកអ៊ាវ "ឌុច"* 001/18-07-2007-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ ០២) ពាក្យសុំរបស់លោក អៀង សារី សុំប្ដឹងជំទាស់ឧត្តមបើលោកសាស្ត្រាចារ្យ Antonio Cassese និងសមាជិកជាក់លាក់មួយចំនួននៃក្រុមប្រឹក្សានិពន្ធ និងគណ:កម្មាធិការនិពន្ធនៃទិនានុប្បវត្តិយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ ដើម្បីកុំឱ្យគាត់ដាក់សារណាជាលាយលក្ខណ៍អក្សរស្ដីពីបញ្ហានៃសហឧក្រិដ្ឋកម្មរួម នៅក្នុងបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញានៃដីកាដំណោះស្រាយ ប្រឆាំងនឹងកាំង ហ្គេកអ៊ាវ "ឌុច" ចុះថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០០៨។ សហមេធាវីការពារក្ដី ជំទាស់លោកសាស្ត្រាចារ្យ Cassese ដោយសារតែទំនាស់ផលប្រយោជន៍យ៉ាងជាក់ស្ដែង-សូម្បីតែមនុស្សពីរនាក់ផ្សេងទៀតដែលជាអ្នកមិនមែនភាគីនៃរឿងក្ដីក៏ពុំអាចបញ្ចេញមតិដោយសេរីឥតលម្អៀងទាក់ទងនឹងធម្មនុរូបនៃការទទួលខុសត្រូវនៃសហឧក្រិដ្ឋកម្មរួម។ លោកសាស្ត្រាចារ្យ Cassese ជាចៅក្រមមួយរូបក្នុងចំណោមចៅក្រមប្រាំរូបនៅក្នុងអង្គជំនុំជម្រះសាលាឧទ្ធរណ៍ក្នុងរឿងក្ដី *Tadić* ដែលសាលដីកាកាលពីថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ១៩៩៩ បញ្ចូលទស្សន:នៃសហឧក្រិដ្ឋកម្មរួមចូលក្នុងសាលាក្ដីព្រហ្មទណ្ឌអន្តរជាតិសម្រាប់យុត្តាធិការនៃអតីតប្រទេសយូហ្គោស្លាវី។ ដោយសារតែលោកសាស្ត្រាចារ្យ Cassese មានតួនាទីបង្កើតសហឧក្រិដ្ឋកម្មរួម និងភាពគ្មាននឿយណាយរបស់គាត់ក្នុងការលើកស្ទួយទស្សន:នេះ ដើម្បីឱ្យគេទទួលស្គាល់វាជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ សហមេធាវីការពារក្ដី សូមជំទាស់ថា ការជ្រើសរើសលោកសាស្ត្រាចារ្យ Cassese ធ្វើជាអ្នកដែលមិនមែនជាភាគីនៃរឿងក្ដី គឺមិនខុសអ្វីពីឱ្យកញ្ជ្រោងទៅយាមទ្រុងមាន់នៃសហឧក្រិដ្ឋកម្មរួម និងមរតកក្នុងសន្ទានុក្រមច្បាប់អន្តរជាតិរបស់គាត់ ដែលមិនមែនជារឿងចៃដន្យនោះទេ។ នៅថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៨ អង្គបុរេជំនុំជម្រះ បដិសេធពាក្យសុំរបស់សហមេធាវីការពារក្ដី ដែលប្ដឹងជំទាស់ឧត្តមបើលោកសាស្ត្រាចារ្យ Cassese និងសមាជិកជាក់លាក់មួយចំនួននៃក្រុមប្រឹក្សានិពន្ធ ដោយសម្អាងថាសហមេធាវីការពារក្ដីពុំមានតួនាទីអ្វីនៅក្នុងរឿងក្ដី *ឌុច*។ *សំណុំរឿងរបស់ កាំង ហ្គេកអ៊ាវ "ឌុច"* 001/18-07-2007-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ ០២) D/99/3/23 សេចក្ដីសម្រេចស្ដីពីពាក្យសុំរបស់លោក អៀង សារី សុំប្ដឹងជំទាស់ឧត្តមបើអ្នកមិនមែនជាភាគីនៃរឿងក្ដី ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៨។

[១០] *សំណុំរឿងរបស់ កាំង ហ្គេកអ៊ាវ "ឌុច"* 001/18-07-2007-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ ០២) សេចក្ដីអញ្ជើញអ្នកដែលមិនមែនជាភាគីនៃរឿងក្ដី ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ D/99/3/13។

[១១] *សំណុំរឿងរបស់ កាំង ហ្គេកអ៊ាវ "ឌុច"* 001/18-07-2007-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ ០២) អ្នកដែលមិនមែនជាភាគីនៃរឿងក្ដីពាក់ព័ន្ធនឹងសំណុំរឿងព្រហ្មទណ្ឌលេខ 001/18-07-2007-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០២) ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៨ D99/3/27។ *សំណុំរឿងរបស់ កាំង ហ្គេកអ៊ាវ "ឌុច"* 001/18-07-2007-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ ០២) សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្ដី ដែលបានដាក់ដោយមជ្ឈមណ្ឌលសម្រាប់សិទ្ធិមនុស្ស និងពហុនិយមគតិយុត្តិ សាកលវិទ្យាល័យ

៥ នៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំនួនបួនក្រុមក្នុងសំណុំរឿង ០០១ កញ្ញា Silke Studzinsky បានដាក់សារណាតបមួយ ដើម្បីឆ្លើយតបទៅនឹងសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដោយលើកទឡ្ហីករណ៍ប្រឆាំងនឹងភាពអាចអនុវត្តបាននៃទម្រង់ទទួលខុសត្រូវនៃសហឧក្រិដ្ឋកម្មរួម[១២]។

៦ នៅថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៨ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីកញ្ញា Silke Studzinsky លោក គឹម ម៉េងឃី កញ្ញា ម៉ុច សុវណ្ណារី លោកស្រី Martine Jacquin និងលោក Philippe Canonne (មេធាវីទាំងបួនរូបខាងក្រោយនេះមកពីខាង Advocats Sans Frontières) បានដាក់សារណាបន្ថែមប្រឆាំងនឹងភាពអាចអនុវត្តបាននៃទម្រង់ទីបីនៃសហឧក្រិដ្ឋរួម[១៣]។

## II- ទឡ្ហីករណ៍

### ក. ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ បានជំទាស់ភាពអាចអនុវត្តបាននៃទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម

៧ ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ ដែលបានជំទាស់នឹងទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម បានពិចារណាលើបញ្ហាចំនួនបី៖ ១) ថាតើការទទួលខុសត្រូវនៃសហឧក្រិដ្ឋកម្មរួមមានចែងនៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះដែរឬយ៉ាងណា ២) ថាតើការទទួលខុសត្រូវនៃសហឧក្រិដ្ឋកម្មរួម

---

McGill ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៨ D99/3/25។ *សំណុំរឿងរបស់ កាំង ហ្គេកអ៊ាវ "ឌុច"* 001/18-07-2007-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ ០២) សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្តីរបស់លោកសាស្ត្រាចារ្យ Antonio Cassese និងសមាជិកនៃវិទិនានុប្បវត្តិយុត្តធម៌ព្រហ្មទណ្ឌអន្តរជាតិ ស្តីពីទ្រឹស្តីសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៨ D99/3/24 ។

[១២] *សំណុំរឿងរប ស់ កាំង ហ្គេកអ៊ាវ "ឌុច"* 001/18-07-2007-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ ០២) សារណាតបរបស់សហមេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងសារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តី ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨ D99/3/32 កថាខណ្ឌ ១៥។

[១៣] សារណាតបរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្តីពីសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៨ D97/3/4។

មានចែងនៅក្នុងច្បាប់កម្ពុជាក្នុងឆ្នាំ ១៩៧៥-៧៩ ដែរឬយ៉ាងណា និង ៣) ថាតើការទទួលខុសត្រូវនៃសហឧក្រិដ្ឋកម្មរួមមានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥-៧៩ ឬយ៉ាងណា៖

**សហឧក្រិដ្ឋកម្មរួមទម្រង់ទីបី មិនមានចែងក្នុងមាត្រា ២៩ នៃច្បាប់ អ.វ.ត.ក ឬនៅក្នុងមាត្រាពាក់ព័ន្ធនៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ទេ។ ដូច្នេះទម្រង់នេះ មិនអាចយកមកអនុវត្តបានទេ។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានលើកឡើង[ផងដែរ]ថា ទ្រឹស្តីសហឧក្រិដ្ឋកម្មរួមទម្រង់ទីបីមិនអាចយកមកអនុវត្តចំពោះមុខ អ.វ.ត.ក ដោយសារទ្រឹស្តីនេះមិនមានចែងក្នុងច្បាប់ទំនៀមទម្លាប់ក្នុងអំឡុងពេលពាក់ព័ន្ធ ឧទាហរណ៍ រវាងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩[១៤] ។**

៨ ពាក់ព័ន្ធនឹងការពិចារណាលើបញ្ហាទី១ ដើមបណ្តឹងរដ្ឋប្បវេណីកត់សម្គាល់ថា លោកសាស្ត្រាចារ្យ Kai Ambos អ្នកដែលមិនមែនជាភាគីនៃរឿងក្តី បានសន្និដ្ឋានក្នុងសារណាដែលគាត់ដាក់ទៅអង្គបុរេជំនុំជម្រះថា ធាតុផ្សំជាក់លាក់នៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី១ ទី២ និងទី៣ មិនមាននៅក្នុងច្បាប់លក្ខន្តិកៈ ប៉ុន្តែមាននៅក្នុងច្បាប់យុត្តិសាស្ត្រទំនៀមទម្លាប់ និងបានគូសបញ្ជាក់ថាពួកគេយល់ស្របតាមជំហរនេះ[១៥] ។ ពាក់ព័ន្ធនឹងការពិចារណាលើបញ្ហាទី២ ដើមបណ្តឹងរដ្ឋប្បវេណីកត់

---

[១៤] ដូចខាងលើ កថាខណ្ឌ ៤-៥ (មានបន្ថែមការគូសចំណាំ)។

[១៥] ដូចខាងលើ កថាខណ្ឌ ១២។ ដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះ បានកត់សម្គាល់ថា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ក្នុងរឿងក្តី *Tadić* បានពឹងផ្អែកលើកម្មវត្ថុ និងគោលដៅនៃលក្ខន្តិកៈរបស់តុលាការ ICTY ដើម្បីសម្រេចថាទម្រង់ទីបីនៃសហឧក្រិដ្ឋរួម អាចជាទម្រង់នៃការប្រព្រឹត្ត ប៉ុន្តែបានគូសបញ្ជាក់ថា ពួកគេមិនយល់ស្របតាមគំនិតនេះទេ ដ្បិតវា"បញ្ច្រាសទៅនឹងគោលគំនិតដែលថាជនជាប់ចោទត្រូវតែផ្តន្ទាទោស"។ ដោយសារតែជនជាប់ចោទត្រូវតែផ្តន្ទាទោស គេត្រូវតែអនុវត្តលក្ខន្តិកៈទៅតាមលក្ខណៈមួយដែលវាអាចផ្តល់លទ្ធផលគួរជាទីពេញចិត្ត។ ទឡ្ហីករណ៍នេះមានលក្ខណៈជារង្វង់ជុំ"។ ដូចខាងលើ កថាខណ្ឌ ១៣។ ពួកគេកត់សម្គាល់ថា "ទោះបីជាមានច្បាប់យុត្តិសាស្ត្ររបស់តុលាការ ICTY ស្តីពីសហឧក្រិដ្ឋកម្មរួម និងមាត្រា ២៥(៣)(ឃ) នៃលក្ខន្តិកៈក្រុងរ៉ូមក្នុងពេលធ្វើសេចក្តីព្រាង និងអនុម័តច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក យ៉ាងណាក្តី ក៏ច្បាប់នេះមិនមែនចែងច្បាស់អំពីសហឧក្រិដ្ឋកម្មរួមថាជាទម្រង់មួយនៃការទទួលខុសត្រូវនោះទេ។ លើសពីនេះ ការលុបចោលសហឧក្រិដ្ឋកម្មរួមយ៉ាងច្បាស់នៅក្នុងច្បាប់ អ.វ.ត.ក ធ្វើឱ្យមានការសន្និដ្ឋានថា សហឧក្រិដ្ឋកម្មរួមមិនត្រូវបានដាក់បញ្ចូលថាជាទម្រង់មួយនៃការទទួលខុសត្រូវទេ"។ ដូចខាងលើ កថាខណ្ឌ ១៤។ សេចក្តីសន្និដ្ឋានក្នុងសារណារបស់លោកសាស្ត្រាចារ្យ Cassese មានលក្ខណៈផ្ទុយគ្នា

សម្គាល់ថា ពួកគេរកមិនឃើញថាច្បាប់កម្ពុជាណាពីឆ្នាំ ១៩៧៥-៧៩ មានចែងពីការទទួលខុសត្រូវដែលស្រដៀងនឹងទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួមនេះទេ[១៦]។ ពាក់ព័ន្ធនឹងការពិចារណាលើបញ្ហាចុងក្រោយ ពាក់ព័ន្ធនឹងបញ្ហាថាតើទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួមមានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងពេលពាក់ព័ន្ធឬយ៉ាងណា- ដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះ សន្និដ្ឋានថាអង្គជំនុំជម្រះសាលាឧទ្ធរណ៍ក្នុងរឿងក្តី *Tadić* ពុំបានធ្វើការវិភាគល្អិតល្អន់មួយពីការអនុវត្តរបស់រដ្ឋ ឬទស្សនៈគតិយុត្តិ មុននឹងសន្និដ្ឋានថាទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួមមានចែងក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ៖

> **យើងអាចសន្និដ្ឋានថា ឧទាហរណ៍ដែលបានចង្អុលយោងនៅក្នុងរឿងក្តី *Tadic* មិនបានបង្កើតជាករណីថា តាមយុត្តិសាស្ត្រជាតិ ឬយុត្តិសាស្ត្រអន្តរជាតិ សហឧក្រិដ្ឋកម្មរួមទម្រង់ទីបី គឺជាច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក៏អះអាងដូចគ្នានេះដែរ។ មិនថាតាមរយៈយុត្តិសាស្ត្រពីមុន ឬការអនុវត្តរបស់រដ្ឋ**

---

ទៅនឹងសេចក្តីសន្និដ្ឋានរបស់លោកសាស្ត្រាចារ្យ Ambos និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែដូចកញ្ញា Silke Studzinsky បានគូសបញ្ជាក់នៅក្នុងសំណុំរឿង ០០១៖ "គោលបំណងនៃសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី គឺដើម្បីជួយចៅក្រមក្នុងការសម្រេចសេចក្តីក្នុងរឿងក្តី។ ដូច្នេះ គេគួរអញ្ជើញអ្នកជំនាញឯករាជ្យ និងអព្យាក្រឹតបាន។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កត់សម្គាល់ឃើញថា អង្គបុរេជំនុំជម្រះបានអញ្ជើញលោកសាស្ត្រាចារ្យបណ្ឌិត Antonio Cassese ដែលជាអតីតចៅក្រមនៅអង្គជំនុំជម្រះសាលាឧទ្ធរណ៍ក្នុងករណី *Tadic* នៅចំពោះមុខសាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ("*ICTY*") ដែលនៅទីនោះទ្រឹស្តីនៃសហឧក្រិដ្ឋកម្មរួម ត្រូវបានគេណែនាំឱ្យប្រើជាលើកដំបូងធ្វើជាទម្រង់នៃការទទួលខុសត្រូវ នៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។ ពិតណាស់ លោកសាស្ត្រាចារ្យបណ្ឌិត Cassese ពិតជាពុំអាចចៀសផុតពីភាពលម្អៀងបានទេ នៅពេលគាត់ដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី ស្តីពីសំណួរដែលសួរថាតើសហឧក្រិដ្ឋកម្មរួមអាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក និងរក្សាជំហរ និងគាំទ្រសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ដែរឬយ៉ាងណា"។ *សំណុំរឿងរបស់ កាំង ហ្កេកអ៊ាវ "ឌុច"* 001/18-07-2007-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ ០២) សារណាតបរបស់សហមេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងសារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តី ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨ D99/3/32 កថាខណ្ឌ ៥។

[១៦] សារណាតបរបស់សហមេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងសារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តី ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨ D99/3/32 កថាខណ្ឌ ១៦-១៧។

**អង្គជំនុំជម្រះសាលាឧទ្ធរណ៍ក្នុងរឿងក្តី *Tadic* មិនបានបង្ហាញអំពីអត្ថិភាពនៃទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួមថាជា"ច្បាប់ទំនៀមទម្លាប់អន្តរជាតិ" [១៧]។**

៩ ដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះ បានសន្និដ្ឋានថា ពុំមានអនុសញ្ញាអន្តរជាតិណាមួយនៅពេលនោះ ដែលគាំទ្រដល់អត្ថិភាពនៃការទទួលខុសត្រូវនៃទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួមទេ និងចុងក្រោយបានគូសបញ្ជាក់ថា៖

> **គោលការណ៍នីត្យានុកូលភាព- ជាគោលការណ៍យុត្តិធម៌ ចែងថាឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវ ដែលដាក់បន្ទុកលើចុងចោទ ត្រូវតែមានអត្ថិភាព ហើយអាចព្យាករណ៍ជាមុនបាន នៅពេលដែលឧក្រិដ្ឋកម្មដូចដែលបានចោទប្រកាន់ បានប្រព្រឹត្តឡើង។ ដោយសារតែពុំមានភ័ស្តុតាងបញ្ជាក់ថាសហឧក្រិដ្ឋកម្មរួមទម្រង់ទីបី មានអត្ថិភាពនៅក្នុងច្បាប់ជាតិ និងមិនមែនជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រឹមឆ្នាំ ១៩៧៥ ការអនុវត្តគោលការណ៍ប្រតិសកម្ម គឺជាការរំលោភបំពានលើគោលការណ៍នីត្យានុកូលភាព [១៨]។**

១០ ជំហររបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះ មានភាពស្របគ្នាទៅនឹងអ្វីដែលអង្គបុរេជំនុំជម្រះបានសម្រេចពាក់ព័ន្ធនឹងភាពមិនអាចអនុវត្តបាននៃទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម [១៩] និងដែលស្របទៅនឹងអ្វីដែលសហមេធាវីការពារក្តីបានដាក់ដើម្បីឆ្លើយតបទៅនឹងសំណើរបស់ ក.ស.ព សុំ"កំណត់"អង្គហេតុឡើងវិញ ដើម្បីដាក់បញ្ចូលការទទួលខុសត្រូវនៃទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម [២០]។ អង្គបុរេជំនុំជម្រះសម្រេចថា៖

---

[១៧] ដូចខាងលើ កថាខណ្ឌ ២៦ (មានគូសបញ្ជាក់បន្ថែម)។

[១៨] ដូចខាងលើ កថាខណ្ឌ ៣១ (មានគូសបញ្ជាក់បន្ថែម)។

[១៩] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ D97/14/15។

[២០] សារណាតបរបស់លោក អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យអង្គជំនុំជម្រះសាលាដំបូងប្រកាសទទួលស្គាល់ទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម ជាជម្រើសមួយទៀតនៃទម្រង់នៃការទទួលខុសត្រូវ និងសំណើសុំសវនាការផ្ទាល់មាត់

**ដោយបានពនិត្យលើឯកសារសម្អាងមូលដ្ឋានផ្លូវច្បាប់ ដែលគេយកមកធ្វើជាសម្អាងក្នុងរឿងក្តី *Tadić* ពាក់ព័ន្ធនឹងទម្រង់ទូលាយនៃសហកម្មឧក្រិដ្ឋកម្មរួម (JCE III) អង្គបុរេជំនុំជម្រះយល់ឃើញថា ឯកសារសម្អាងទាំងនោះពុំមានផ្តល់នូវភ័ស្តុតាងគ្រប់គ្រាន់អំពីការអនុវត្តរបស់រដ្ឋ និងទស្សនៈគតិយុត្តិ ដែលមានលក្ខណៈទូលំទូលាយនិងស៊ីគ្នាឡើយ នៅពេលវេលាដែលពាក់ព័ន្ធសម្រាប់សំណុំរឿង ០០២។ អង្គបុរេជំនុំជម្រះសន្និដ្ឋានថា សហឧក្រិដ្ឋកម្មរួមទម្រង់ទីបី មិនត្រូវបានទទួលស្គាល់ជាទម្រង់នៃការទទួលខុសត្រូវ ដែលអាចអនុវត្តបានការរំលោភបំពានលើច្បាប់មនុស្សធម៌អន្តរជាតិឡើយ...**[២១]

១១ អង្គបុរេជំនុំជម្រះ យល់ស្របជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះដែរ ដ្បិតខ្លួនមិនអាចរកឃើញបទប្បញ្ញត្តិណាមួយនៃច្បាប់កម្ពុជា ដែលចែងដូចគ្នានឹងទៅនឹងការទទួលខុសត្រូវទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួមនេះទេ[២២] និងខ្លួនមិនអាចរកឃើញភ័ស្តុតាងអំពីការអនុវត្តរបស់រដ្ឋ និងទស្សនៈគតិយុត្តិ ដើម្បីសន្និដ្ឋានថាទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួមមានចែងក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះដែរ[២៣]។ សហមេធាវីការពារក្តី និងអ្នកប្រាជ្ញជាច្រើនយល់ស្របតាមទស្សនៈនេះ។ អតីតចៅក្រម Wolfgang Schomburg នៃអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY/ICTR

---

ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ E100/2។ [ខៀវ សំផន] Réponse à la Demande des Co-Procureurs Relative à la Troisième Catégorie d'Entreprise Criminelle Commune, ២២ ខែ កក្កដា ឆ្នាំ ២០១១, E100/3។ [អៀង ធីរិទ្ធ] ចម្លើយតបរបស់សហមេធាវីការពារក្តី តបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូងប្រកាសទទួលស្គាល់ទម្រង់ទីបីនៃសហឧក្រិដ្ឋរួម ជាជម្រើសមួយទៀតនៃទម្រង់នៃការទទួលខុសត្រូវ ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ E100/1។ [នួន ជា] សារណាតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូងប្រកាសទទួលស្គាល់ទម្រង់ទីបីនៃសហឧក្រិដ្ឋរួម ជាជម្រើសមួយទៀតនៃទម្រង់នៃការទទួលខុសត្រូវ ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ E100/5។

[២១] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ D97/14/15 កថាខណ្ឌ ៧៧ (មានគូសបញ្ជាក់បន្ថែម)

[២២] ដូចខាងលើ កថាខណ្ឌ ៨៧

[២៣] ដូចខាងលើ កថាខណ្ឌ ៧៧-៨៣

បានបញ្ជាក់ថា៖ "យុត្តិសាស្ត្រដែលគេបានយោង(និងដែលមានកម្រិត) [ក្នុងរឿងក្តី *Tadić*] មានភាពចម្រូងចម្រាស់គ្នាខ្លាំងពេក ដែលមិនអាចឱ្យគេសម្រេចបានថា ទម្រង់ទាំងបីនៃសហឧក្រិដ្ឋកម្មរួមនេះ បង្កើតបានជាច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេ[២៤]" ស្របពេលដែលសាស្ត្រាចារ្យ Jens David Ohlin គូសបញ្ជាក់ថា៖ "មូលដ្ឋានគ្រឹះនៃច្បាប់យុត្តិសាស្ត្រសម្រាប់ទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម មានភាពមិនរឹងប៉ឹង... តាមពិត ពុំមានករណីអន្តរជាតិណាមួយត្រូវបានគេដកស្រង់យោងក្នុងមតិយោបល់ក្នុងរឿងក្តី *Tadic* ដែលសន្និដ្ឋានភាសានៃការទទួលខុសត្រូវចំពោះសកម្មភាពដែលគេអាចព្យាករណ៍ជាមុនបានសមហេតុផលនោះទេ"[២៥]។

១២ សារណានោះ ពុំបានបញ្ជាក់ ឬបង្ហាញ ថាជំហររបស់ដើមបណ្តឹងរដ្ឋប្បវេណីមិនត្រឹមត្រូវ ឬគួរងាកចេញពីវាឬយ៉ាងណានោះទេ។ សារណានោះមានគូសបន្ទាត់សម្រាប់ហត្ថលេខារបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពេជ្រ អង្គ និង Elisabeth Simmonneau Fort និងសម្រាប់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ម៉ុច សុវណ្ណារី គីម ម៉េងឃី និង Isabelle Durand។ ក្នុងចំណោមអ្នកទាំងអស់នេះ មានតែសហមេធាវី ម៉ុច សុវណ្ណារី គីម ម៉េងឃី និង Isabelle Durand ប៉ុណ្ណោះបានចុះហត្ថលេខាលើសារណា។ ម៉ុច សុវណ្ណារី និង គីម ម៉េងឃី មើលទៅដូចជាងាកចេញពីជំហររបស់ខ្លួនកាលពីពេលមុន ដែលថាទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម មិនអាចអនុវត្តបាននៅ អ.វ.ត.ក (ដោយពុំបានបញ្ជាក់ឱ្យច្បាស់អំពីការលះបង់ជំហរនេះទេ) ប៉ុន្តែពុំមានភ័ស្តុតាងបញ្ជាក់ថាសហមេធាវី Silke Studzinsky បានធ្វើដូច្នេះដែរនោះទេ។ តាមពិតសារណានោះ ទើបតែត្រូវបានកែក្នុងពេលថ្មីៗនេះ ជាពិសេសដើម្បីដកឈ្មោះគាត់ចេញពីបញ្ជីសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលដាក់ឯកសារ ដោយយកទៅដាក់នៅទំព័រមុខត្រង់ផ្នែកនៃបញ្ជីឈ្មោះអ្នកទទួលឯកសារវិញ[២៦]។ ប្រការនេះសបញ្ជាក់ឱ្យឃើញអំពីភាពខ្វះការយល់

[២៤] ចៅក្រម Wolfgang Schomburg *យុត្តិសាស្ត្រស្តីពីសហឧក្រិដ្ឋកម្មរួម ការពិនិត្យឡើងវិញនូវរឿងរ៉ាវដែលមិនចេះចប់* អ្នកត្រួតពិនិត្យសាលាក្តីកម្ពុជា ថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ២០១០ ទំព័រ ២។

[២៥] Jens David Ohli *ចេតនារួម ដើម្បីប្រព្រឹត្តបទឧក្រិដ្ឋអន្តរជាតិ* 11 CHI. J. INT'L L. 693, 707-08 (2011)។

[២៦] សូមមើលសំណើសុំកែលើឯកសារ E100/4 ជាភាសាអង់គ្លេស E100/4. Corr-1, ថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១១។

ស្របគ្នារវាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងភាពអាចអនុវត្តបាននៃទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួមនៅ អ.វ.ត.ក។

## ខ. ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០១ បានជំទាស់ទៅនឹងការអនុវត្តទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម

១៣ ក្នុងសំណុំរឿង ០០១ ក្រុមដើមបណ្តឹងរដ្ឋប្បវេណីជាក់លាក់មួយចំនួន ក៏បានជំទាស់ទៅនឹងការអនុវត្តនៃទម្រង់នៃការទទួលខុសត្រូវនៃទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួមនេះដែរ។ ក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីចំនួនបួនក្នុងសំណុំរឿង ០០១ មានដើមបណ្តឹងរដ្ឋប្បវេណីពីរក្រុមជំទាស់ការអនុវត្តទម្រង់នេះ។

១៤ សហមេធាវី Silke Studzinsky (តំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៤) បានលើកទឡ្ហីករណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះ ដើម្បីឆ្លើយតបទៅនឹងសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីស្តីពីភាពអាចអនុវត្តបាននៃទម្រង់ទាំងបីនៃសហឧក្រិដ្ឋកម្មរួម ថា"ទ្រឹស្តីនៃសហឧក្រិដ្ឋកម្មរួមជាពិសេសទម្រង់ពន្លាតរបស់វា ពុំបង្កើតបានជាច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងពេលពាក់ព័ន្ធនោះទេ"[២៧]។

១៥ ដូចគ្នានេះដែរ សហមេធាវី Karim Khan QC តំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ បានបញ្ជាក់ក្នុងអំណះអំណាងបិទរបស់គាត់ ដើម្បីពន្យល់ថា ដើមបណ្តឹងរដ្ឋប្បវេណីពុំមែនជាព្រះរាជអាជ្ញាបន្ថែម នោះថា៖

---

[២៧] *សំណុំរឿងរបស់ កាំង ហ្គេកអ៊ាវ "ឌុច"* 001/18-07-2007-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ ០២) សារណាតបរបស់សហមេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងសារណារបស់អ្នកដែលមិនមែនភាគីក្នុងរឿងក្តី ចុះថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ២០០៨ D99/3/32 កថាខណ្ឌ ១៥។

ខ្ញុំពិតជានៅចាំថា នៅដំណាក់កាលដំបូងនៃកិច្ចដំណើរការនីតិវិធីនេះក្នុងខែ កុម្ភៈ ខាងសហព្រះរាជអាជ្ញាប៉ុនប៉ងដាក់បញ្ចូលទ្រឹស្តីសហឧក្រិដ្ឋកម្មរួម។ នៅក្នុងឱកាសនោះដែរ ខ្ញុំបានជម្រាបពីខរក្សាសិទ្ធិរបស់ខ្ញុំ ហើយខ្ញុំបានកត់សម្គាល់ឃើញថា លោក Rouge និងក្រុមសហមេធាវីការពារក្តីឱ្យជនជាប់ចោទ បានលើកឡើងអំពីបញ្ហាសហឧក្រិដ្ឋកម្មនេះនៅក្នុងសារណារបស់ខ្លួន។ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ ពុំបានដាក់ឯកសារគាំទ្រការបញ្ចូលទ្រឹស្តីនោះទៅក្នុងកិច្ចដំណើរការនីតិវិធីទាំងនេះទេ[២៨]។

## III- សេចក្តីសន្និដ្ឋាន និងសំណើសុំ

១៦ សារណានោះធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងយល់ខុស ក្នុងការសន្និដ្ឋានថា ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ប្រកាន់ជំហរមួយថា ការទទួលខុសត្រូវនៃទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួមអាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក។ សារណាមុនៗរបស់ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន បង្ហាញផ្ទុយពីនេះ។ ការទទួលស្គាល់ ឬសេចក្តីពន្យល់ ពុំឃើញមានផ្តល់ជូននោះទេ។ ជាការពិតណាស់ ដើមបណ្តឹងរដ្ឋប្បវេណីជាក់លាក់មួយចំនួនក្នុងសំណុំរឿង ០០២ និង ០០១ ពិតជាបានវិភាគល្អិតល្អន់លើបញ្ហានេះ និងបានសម្រេចថាទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម មិនអាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក នោះទេ។ សារណានោះ ពុំបានទទួលស្គាល់ចំណុចនេះ និងពុំបានស្វះស្វែងរកការពន្យល់នូវភាពមិនស៊ីសង្វាក់គ្នាពាក់ព័ន្ធនឹងជំហរដែលខ្លួនបានលើកឡើងនោះទេ។

**អាស្រ័យដូចបានបញ្ជាក់ក្នុងមូលហេតុខាងលើ** សហមេធាវីការពារក្តី ស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង៖

---

[២៨] *សំណុំរឿងរបស់ កាំង ហ្គេកអ៊ាវ "ឌុច"* 001/18-07-2007-អ.វ.ត.ក/អ.ជ.ស.ដ ប្រតិចារិកកិច្ចដំណើរការនីតិវិធី កាំង ហ្គេកអ៊ាវ "ឌុច" សាធារណៈ-កោសលុប ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៩ E1/78.1 ទំព័រទី ៦ 1.1- 9 (មានបន្ថែមការគូសបញ្ជាក់)

ក. **កត់សម្គាល់** ភាពមិនស៊ីសង្វាក់គ្នារវាងសារណា និងទឡ្ហីករណ៍ដែលធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីជាក់លាក់មួយចំនួនក្នុងសំណុំរឿង ០០១ និង ០០២ ពាក់ព័ន្ធនឹងភាពអាចអនុវត្តបាននៃការទទួលខុសត្រូវនៃទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួម និង

ខ **បង្គាប់** ឱ្យសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ម៉ុច សុវណ្ណារី និង គីម ម៉េងឃី ពន្យល់ថាតើ ពួកគាត់ពិតជាបានងាកចេញពីជំហរពីមុនរបស់ខ្លួន ប្រឆាំងនឹងភាពអនុវត្តបាននៃទម្រង់ទីបីនៃសហឧក្រិដ្ឋកម្មរួមនេះឬយ៉ាងណា។ ប្រសិនបើពួកគាត់ពិតជាងាកចេញពីជំហរមុនមែន សូមបង្គាប់ឱ្យពួកគាត់បញ្ជាក់អំពីសម្អាងហេតុផ្លូវច្បាប់ ដែលពួកគាត់យកមកធ្វើជាមូលដ្ឋានសម្អាងសម្រាប់ការផ្លាស់ប្តូរជំហររបស់ខ្លួនក្នុងពេលបច្ចុប្បន្ននេះ។

សូមដាក់សំណើជូនដោយក្តីគោរព

| | |
|---|---|
| អាង ឧត្តម | Michael G. KARNAVAS |

សហមេធាវីការពារក្តីរបស់លោក អៀង សារី

ចុះហត្ថលេខានៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី៥ ខែ សីហា ឆ្នាំ ២០១១